**សេចក្តីជូនដំណឹងដល់សិក្ខាកាមទាំងអស់**

厚生労働省

## នេះជាពត៌មានណែនាំប្រសិនបើសិក្ខាកាមមិនអាចបន្តធ្វើការនៅក្នុងប្រទេសជប៉ុន

ក្នុងនាមជាសិក្ខាកាម  អ្នកត្រូវបានការពារដោយច្បាប់ការងាររបស់រដ្ឋាភិបាលក្នុងប្រទេសជប៉ុន។ប្រសិនបើសិក្ខាកាមមិនអាចបន្តធ្វើការងារដោយសារការរីករាលដាលនៃជំងឺឆ្លងថ្មីកូរ៉ូណានេះ  សិក្ខាកាមអាចប្រើប្រាស់ប្រព័ន្ធដូចខាងក្រោមបានដែរហើយសូមកុំស្ទាក់ស្ទើរក្នុងការប្រើប្រាស់វា។

## ប្រាក់ជំនួយនៃការធានារ៉ាប់រងការងារ(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)

**ក្នុងអំឡុងពេលអ្នកធ្វើការបានបាត់បង់ការងារយើងផ្តល់អត្ថប្រយោជន៍ចាំបាច់ដើម្បីធ្វើឱ្យជីវិតរបស់ពួកគេអាចរស់នៅបានដោយមានស្ថេរភាព។ ប្រសិនបើអ្នកគ្មានការងារធ្វើដោយសារខាងក្រុមហ៊ុនបានក្ស័យធនហើយលំបាកក្នុងការរកការងារថ្មី  បើអ្នកមានលក្ខខណ្ឌជាក់លាក់មិនចំពោះសិក្ខាកាមនោះទេអ្នកអាចស្នើរជំនួយយកប្រាក់ធានារ៉ាប់រងការងារបាន (ប្រាក់លើកទឹកចិត្តមូលដ្ឋាន) ។ (ចំណាំសិក្ខាកាមក៏មានសិទ្ធប្រើប្រាស់ប្រព័ន្ធនេះដូចជនជាតិជប៉ុនផងដែរ)**

### ១ ការដាក់ពាក្យធ្វើការនៅកន្លែងស្វែងរកការងារ

ដើម្បីទទួលបានប្រាក់ឧបត្ថម្ភមូលដ្ឋានបន្ទាប់ពីឈប់រឺចាកចេញពីការងារអ្នកត្រូវដាក់ពាក្យសុំរកការងារនៅកន្លែងស្វែងរកការងារ។

### ២ ការធានារ៉ាប់រងការងារត្រូវមានរយៈពេល១២ខែឬច្រើនជាងនេះ

បន្ទាប់ពីចាកចេញពីការងារអ្នកត្រូវតែមានការបង់ធានារ៉ាប់រងការងារយ៉ាងហោចណាស់១២ខែក្នុងរយៈពេល២ឆ្នាំមុនថ្ងៃដែលបានចាកចេញពីការងារ។ប៉ុន្តែបើសិនជាខាងក្រុមហ៊ុនមិនមានការក្ស័យធុនទេតែក្រុមហ៊ុនត្រូវបញ្ឈប់បុគ្គលិកមួយចំនួនទោះការធានារ៉ាប់រងការងារត្រូវមានយ៉ាងហោចណាស់៦ខែក្នុងរយៈពេល១ឆ្នាំមុនថ្ងៃចាកចេញពីការងារ។

**<វិធីស្នើសុំយកការធានារ៉ាប់រង(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)>**

- ចាកចេញពីការងារ
- ពាក្យសុំការងារនិងការកំណត់អំពីសិទ្ធិ — សមីខ្លួនត្រូវយកឯកសារដែលត្រូវការទៅដាក់នៅកន្លែងស្វែងរកការងារ។
- ការពន្យល់អំពីការធានារ៉ាប់រង — ប្រគល់ឯកសារនឹងវិញ្ញាបនប័ត្រនៃសិទ្ធិទទួលប្រាក់ជំនួយ។ ពន្យល់ពីវិធីបន្តនៃការធានារ៉ាប់រងការងារ ។
- ការផុតកំណត់រយៈពេលរង់ចាំ — ចាប់ពីថ្ងៃដាក់ពាក្យរយៈពេល៧ថ្ងៃគឺមិនបានគិតនៃការរង់ចាំក្នុងការទទួលប្រាក់ធានារ៉ាប់រងការងារឡើយ។
- ការកំណត់ប្រាក់ជំនួយ — ប្រសិនបើអ្នកឈប់ការងារដោយផ្ទាល់ខ្លួនអ្នកមិនមានសិទ្ធស្នើសុំការធានារ៉ាប់រងការងាររយៈពេល៣ខែបន្ទាប់ពីឈប់ការងារ។
- វិញ្ញាបនប័ត្រអត់ការងារធ្វើ — ការទទួលស្គាល់អត់ការងារ(គោលការណ៍៤សប្តាហ៍ម្តង)  ត្រូវយកឯកសារទៅកន្លែងស្វែងរកការងារ។
- ទូទាត់ប្រាក់លើកទឹកចិត្តមូលដ្ឋាន — ប្រាក់លើកទឹកចិត្តមូលដ្ឋាននឹងផ្ទេរទៅធនាគាររបស់អ្នកនៃចំនួនថ្ងៃសរុបដែលអ្នកអត់មានការងារធ្វើ។
- តាមច្បាប់កាលបរិច្ឆេទនៃការបញ្ជាក់របស់អ្នកនឹងត្រូវបានបញ្ជាក់រៀងរាល់៤សប្តាហ៍ម្តង
- ផ្លាស់ប្តូរការងារថ្មី
- បញ្ឈប់ការបើកប្រាក់

ក្រុមហ៊ុនដែលត្រូវបានកាត់បន្ថយម៉ោងធ្វើការរបស់បុគ្គលិកហើយអាចឈានដល់ការបញ្ឈប់បុគ្គលិកក្នុងករណីណាមួយពួកគេអាចស្នើរប្រាក់ឧបត្ថម្ភបានដែលតំរូវអោយពួកគេបំពេញតាមតម្រូវការជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយដើម្បីចៀសវាងគុណវិបត្តិបុគ្គលិកពួកគេអាចប្រើប្រាស់ប្រព័ន្ធធានារ៉ាប់រងការងារពេលឈប់សម្រាកបាន។

※ លើសពីនេះទៅទៀតក្នុងមេត្រាទី២៦នៃច្បាប់ស្ដីពីស្តង់ដារការងារប្រសិនបើក្រុមហ៊ុនបានបញ្ឈប់បុគ្គលិកពួកគេត្រូវទទួលប្រាក់ជំនួយពីក្រុមហ៊ុនក្នុងរយៈពេលឈប់សម្រាកដើម្បីធានាកំរិតជីវភាពអប្បបរមាររបស់បុគ្គលិកដែលបានសន្មត់ជាមុន។

**សម្រាប់ពតិមានបន្ថែមសូមទាក់ទងសាកសួរខាងក្រោមហើយយើងក៏ផ្តល់ពត៌មានតាមគេហទំព័រផងដែរ**

●**ប្រាក់ជំនួយនៃការធានារ៉ាប់រងការងារ(ប្រាក់លើកទឹកចិត្តមូលដ្ឋាន)：**

➢**ការិយាល័យសន្តិសុខការងារសាធារណះការិយាល័យរដ្ឋបាលខេត្ត （កន្លែងស្វែងរកការងារ）**

**https://www.mhlw.go.jp/kyujin/hwmap.html**

●**សូមទំនាក់ទំនងទៅល័ក្ខខ័ណ្ឌការងារប្រាក់ឈ្នួលរួមទាំងប្រាក់ជំនួយពេលឈប់សម្រាក：**

➢**ទូរស័ព្ទពិភាគសារយោបល់សម្រាប់ពលករបរទេស ទូរស័ព្ទបន្ទាន់សម្រាប់ពិគ្រោះយោបល់ល័ក្ខខ័ណ្ឌការងារនឹងពិគ្រោះយោបល់សម្រាប់ជនបរទេស：**

**https://www.check-roudou.mhlw.go.jp/soudan/foreigner.html**

## សេចក្ដីណែនាំរបស់អង្គការបណ្តុះបណ្តាលបច្ចេកទេសនឹងបណ្តាញទូរស័ព្ទពិគ្រោះយោបល់នៃភាសាដើមកំណើត

អង្គការបណ្តុះបណ្តាលបច្ចេកទេសបរទេស

・ពេលមានអារម្មណ៍ព្រួយចំពោះការងារឬជីវភាពប្រចាំថ្ងៃ

・ពេលមានអារម្មណ៍ថាប្រាក់ឈ្នួលការងារមិនទទួលបានគ្រប់គ្រាន់រឺខុសតាមគោលការណ៍

・ពេលមានកំហុសឆ្គងហើយនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសវិញ

・ពេលដែលមិនយល់ច្បាស់អំពីច្បាប់ប្រទេសជប៉ុនរឺមិនមាននរណាម្នាក់ពិគ្រោះយោបល់ជាមួយ

ទទួលពិគ្រោះយោបល់ជាច្រើនរបស់សិក្ខាកាមពលករនៅប្រទេសជប៉ុនជាមួយភាសាដើមកំនើតរបស់អ្នក

សម្រាប់ពត៏មានសម្អិតសុមចុលមើលគេហទំព័រខាងក្រោម（https://www.otit.go.jp）

**ទូរស័ព្ទពិគ្រោះយោបល់ជាភាសារកំនើត （១១:00～១៩:00ល្ងាច）**

・ភាសាវៀតណាម រាល់សប្តាហ៍：ច័ន្ទ～សុក្រ TEL：០១២០－២៥០－១៦៨

・ភាសាចិន រាល់សប្តាហ៍ ：ច័ន្ទ・ពុធ・សុក្រ TEL：០១២០－២៥០－១៦៩

・ភាសាឥណ្ឌូនេស៊ី រាល់សប្តាហ៍ ：អង្គារ・ពុធ TEL：០១២០－២៥០－១៩២

・ភាសាហ្វីលីពីន រាល់សប្តាហ៍ ：អង្គារ・សៅរ៍ TEL：០១២០－២៥០－១៩៧

・ភាសាអង់គ្លេស រាល់សប្តាហ៍ ：អង្គារ・សៅរ៍ TEL：០១២០－២៥០－១៤៧

・ភាសាថៃ រាល់សប្តាហ៍ ：ពុធ・ សៅរ៍ TEL：០១២០－២៥០－១៩៨

・ភាសាខ្មែរ រាល់សប្តាហ៍ ：ព្រហស្បហ៍ TEL：១២០－២៥០－៣៦៦

・ភាសាមិយ៉ាន់ម៉ា រាល់សប្តាហ៍ ：សុក្រ TEL：០១២០－២៥០－៣០២